

# ជំពូកទី ៣

# គោលការណ៍ណែនាំទូទៅ សំរាប់សកម្មភាពសិក្សា

នៅក្នុងជំពូកនេះមានពន្យល់អធិប្បាយអំពីគោលការណ៍ណែនាំទូទៅមួយចំនួន ដែលឪពុកម្ដាយបានរកឃើញថាមាន ប្រយោជន៍ នៅពេលបង្រៀនបំណិនថ្មីដល់កូនរបស់គាត់ ។ ចូរព្យាយាមប្រើគោលការណ៍ទាំងនេះបន្ថែមទៀតចំពោះការបង្ហាត់បង្រៀនជាក់លាក់សំរាប់សកម្មភាពនីមួយៗនៅក្នុងជំពូកទី 5 ដល់ជំពូកទី 8, ព្រមទាំងជំពូកទី 10, និងជំពូកទី 11 ។

## អ្នកគឺជាបុគ្គលជំនាញអំពីកូនរបស់អ្នក

គ្មាននរណាស្គាល់កូនរបស់អ្នកនិងលទ្ធភាពទាំងឡាយរបស់គេច្បាស់ជាងអ្នកឡើយ ។ ចូរស្ដាប់តាមអារម្មណ៍ និង បទពិសោធន៍របស់អ្នកអំពីកូនអ្នកយ៉ាងណា ទោះបីជាអារម្មណ៍និងបទពិសោធន៍របស់អ្នកខុសពីអ្វីដែលវេជ្ជបណ្ឌិត, បុគ្គលិក-សុខាភិបាល, គ្រូបង្រៀន ឬ សៀវភៅនេះបានប្រាប់អ្នកក៏ដោយ ។ អ្នកអាចរៀនយ៉ាងច្រើនពីមនុស្សដែលមានបទពិសោធន៍ ជាមួយកុមារមានបញ្ហាគំហើញ ប៉ុន្ដែកុមារគ្រប់រូបគឺខុសៗគ្នា ។ អ្នកគឺជាបុគ្គលជំនាញអំពីកូនរបស់អ្នក ។

## ឱ្យកូនធ្វើជាអ្នកនាំមុខ

ការលេងគឺជាវិធីសំខាន់មួយសំរាប់ឱ្យកុមាររៀនសូត្រពីព្រឹត្តិការណ៍ទាំងឡាយនៅជុំវិញ ។ កុមារជក់ចិត្តចង់លេង កាន់តែខ្លាំង កាលណាគេបានធ្វើអ្វីមួយដែលគេពេញចិត្ត ។ ដូច្នេះបើកូនអ្នកបង្ហាញចំណាប់អារម្មណ៍លេងជាមួយវត្ថុ មនុស្ស ឬ សកម្មភាពណាមួយនោះ ចូរប្រើការលេងកំសាន្តរបស់កូនដើម្បីបង្រៀនបំណិនថ្មីៗដល់កូនអ្នក ។

ការឱ្យកូនធ្វើជាអ្នកនាំមុខ ជួយកូនឱ្យដឹងថាជំរើសរបស់គេគឺជាការសំខាន់ ហើយគេមានអំណាចមួយចំនួនលើអ្វីដែល កើតឡើង ។ ប៉ុន្ដែមិនមានន័យថាអ្វីៗទាំងឡាយមិនបានគ្រោងមុននោះទេ ។ អ្នកត្រូវការគិតអំពីបំណិនដែលកូនអ្នកត្រូវការ រៀន (ចូរអានទំព័រ 12) អំពីប្រភេទសកម្មភាព និងវត្ថុទាំងឡាយដែលអាចជួយកូនរៀនបំណិនទាំងនេះ ។ បន្ទាប់មកអ្នកអាច រិះគិតរកវិធីនានាដើម្បីជួយកូនរៀនបំណិនថែមទៀត ខណៈដែលគេកំពុងលេងកំសាន្ដ ។



## សម្របសម្រួលសកម្មភាពឱ្យសមស្របសំរាប់កូនអ្នក

កុមារអាចរៀនបំណិនពិតប្រាកដមួយតាមវិធីជាច្រើនខុសៗគ្នា។ អ្នកអាចយកសកម្មភាពនានានៅក្នុងសៀវភៅមកកែសម្រួលឱ្យសមស្របបំផុតសំរាប់កូនអ្នក, ក្រុមគ្រួសារអ្នក, និងសហគមន៍របស់អ្នក។



ខណៈដែលអ្នកអនុវត្តសកម្មភាពទាំងនេះជាមួយកូន អ្នកនឹងរកឃើញវិធីសំរាប់ធ្វើអ្វីៗដែលទាក់ទាញអារម្មណ៍កូនឱ្យជក់ចិត្តនិងឱ្យគេចង់ធ្វើអ្វីមួយ...




...ហើយអ្នកនឹងដឹងនូវអ្វីដែលធ្វើឱ្យកូនអន់ចិត្ត ឬ ធ្វើឱ្យកូនចង់ឈប់ធ្វើកិច្ចការនោះ។






អ្នកអាចយកសកម្មភាពនានាមកកែសម្រួល ដោយប្រើសម្ភារៈដែលអ្នកមានស្រាប់។ ឧទាហរណ៍ បើសិនជាសកម្មភាពមួយនៅក្នុងសៀវភៅនេះបង្ហាញថា ក្មេងកំពុងប្រើប្រដាប់លេងមួយ អ្នកមិនចាំបាច់រក ឬ ទិញប្រដាប់លេងឱ្យដូចគ្នាឡើយ។ ចូរប្រើរបស់អ្វីៗដែលអ្នកមានស្រាប់ជំនួសវាវិញ។

ចូរកែសម្រួលសកម្មភាពដែលធ្វើយ៉ាងណាឱ្យសមស្របនឹងកិច្ចការប្រចាំថ្ងៃរបស់អ្នក និងសកម្មភាពនៃក្រុមគ្រួសារ និងការរស់នៅរបស់អ្នក ។




## ដំបូងអ្នកត្រូវសាកល្បងសកម្មភាពដោយខ្លួនឯងសិន

នៅពេលអ្នកត្រៀមរៀបចំបង្រៀនកូន ចូរសាកល្បងធ្វើសកម្មភាព និងគិតអំពីជំហានទីមួយៗដោយខ្លួនឯងសិន ។ ប្រការនេះនឹងជួយអ្នករិះគិតនូវវិធីដែលល្អបំផុតដើម្បីបង្រៀនកូនអ្នក ។



ឪពុកម្នាក់នេះកំពុងរៀនដោយខ្លួនឯងពីរបៀប ហូបចុកដោយមិនចាំបាច់ប្រើភ្នែកមើល ។



ឪពុកម្នាក់នេះកំពុងរៀនដោយខ្លួនឯងពីរបៀបហូបចុក ពេលដែលគាត់អាចមើលឃើញជ្រុងម្ខាងតែប៉ុណ្ណោះ។

## ធ្វើការពីក្រោយខ្នងកូនអ្នក




នៅពេលអ្នកកំពុងបង្ហាញកូនអំពីរបៀបធ្វើសកម្មភាពថ្មីមួយដូចជា ការហូបចុក ឬ ស្លៀកពាក់ដោយខ្លួនឯង ។ កូនអ្នកប្រហែលជាងាយយល់ច្រើនអំពីចលនារបស់អ្នក បើសិនជាអ្នកធ្វើនៅពីក្រោយខ្នងកូន ។ ជួនកាលវាមានដំណើរការល្អ បើអ្នកដាក់ដៃរបស់អ្នកលើដៃកូន ប៉ុន្តែត្រូវសួរកូនជាមុនសិន បើកូនយល់ព្រម ។

## ចូរធ្វើឱ្យមានស្ថេរភាព

នៅរាល់ពេលបង្រៀនបំណិននីមួយៗ ចូរព្យាយាមបង្រៀនតាមវិធីដូចគ្នា ទាំងការប្រើពាក្យ និងជំហានដូចគ្នា ។ អ្នកនឹងត្រូវការអនុវត្តប្រភេទសកម្មភាពខុសៗគ្នា ពីព្រោះកុមារមិនអាចផ្តោតការយកចិត្តទុកដាក់លើសកម្មភាពមួយក្នុងរយៈពេលវែងបានឡើយ ។ ចូរព្យាយាមកុំប្តូរវិធីដែលអ្នកនិយាយក្នុងពេលបង្រៀនបំណិននីមួយៗ ។ វាក៏ជាជំនួយផងដែរបើការចាប់ផ្តើមនិងការបញ្ចប់សកម្មភាពជាមួយពាក្យដូចគ្នា ឬ សកម្មភាពដូចគ្នា ។ ប្រការនេះក្មេងនឹងដឹងថាសកម្មភាពគឺកំពុងផ្លាស់ប្តូរ ។




**ឪពុករបស់សុភី និយាយពាក្យទាំងនេះរាល់ពេលដែលក្រុមគ្រួសារបញ្ចប់ការបរិភោគអាហារពេលល្ងាច។**

## ឱ្យពេលគ្រប់គ្រាន់ដល់កូន




យ៉ាងហោចណាស់ក៏នៅលើកដំបូងដែរ ដែលកុមារមានបញ្ហាគំហើញចំណាយពេលយូរក្នុងការធ្វើអ្វីៗទាំងឡាយ ។ គេត្រូវការពេលដើម្បីគិតនូវអ្វីដែលអ្នកបានស្នើឱ្យគេធ្វើ និងអំពីអ្វីដែលគេត្រូវឆ្លើយតបទៅវិញ ។ ដូច្នេះចូរធ្វើយ៉ាងណាផ្ដល់ពេលឱ្យបានគ្រប់គ្រាន់ដល់កូនដើម្បីឱ្យកូនទទួលជោគជ័យនូវអ្វីដែលគេធ្វើ ។




## ចូរឱ្យកូនបានដឹងថាគេធ្វើដល់ណាហើយ

កុមារមើលឃើញមិនច្បាស់ មិនអាចមើលឃើញថាគេធ្វើកិច្ចការជិតចប់នោះទេ ដូច្នេះគេត្រូវការអ្នកប្រាប់គេឱ្យបានដឹង ។ បើមិនអញ្ចឹងទេ កុមារអាចបាត់បង់ទឹកចិត្តដោយមិនដឹងថាគេធ្វើបានប៉ុណ្ណាហើយ ។ នៅពេលកុមារធ្វើអ្វីមួយបានល្អ ចូរនិយាយសរសើរឱ្យគេបានដឹង ។ កុមារគ្រប់រូបត្រូវការពាក្យសម្ដីសរសើរដល់គេ ។




## ឱ្យកូនដឹងនូវអ្វីៗទាំងឡាយកំពុងកើតឡើងជុំវិញខ្លួនគេ

កុមារភ្នែកភ្លឺដឹងអំពីអ្វីៗជាច្រើនដែលកំពុងកើតឡើងនៅជុំវិញខ្លួនគេ ។ ឧទាហរណ៍ កុមារដឹងថាតើនរណានៅក្នុងបន្ទប់ នរណាកំពុងនិយាយអ្វីដែលមនុស្សដទៃកំពុងធ្វើ និងកន្លែងដែលប្រភពសម្លេងបន្លឺចេញ ។ កុមារពិការភ្នែករៀនប្រើប្រាស់វិញ្ញាណទាំងឡាយដើម្បីឱ្យដឹងអំពីហេតុការណ៍ដ៏ច្រើនទាំងនេះដូចគ្នា ។ អ្នកអាចជួយក្មេងឱ្យរៀនអំពីអ្វីៗនៅជុំវិញខ្លួនគេដោយការរៀបរាប់ប្រាប់ និងការបង្ហាញនូវអ្វីដែលកំពុងកើតឡើងដល់កុមារ ។

## ចូរចងចាំរបៀបដែលកុមាររៀនសូត្រ

នៅពេលអ្នកកំពុងបង្រៀនបំណិនថ្មីមួយដល់កុមារ គេនឹងរៀនវាទៅតាមដំណាក់កាលជាច្រើន ។

មុនដំបូងកុមាររៀនបំណិននេះដោយមានការជួយជ្រោមជ្រែង ។




បន្ទាប់មកគេចងចាំរបៀបធ្វើកិច្ចការទាំងអស់នោះដោយខ្លួនឯងផ្ទាល់ ។



ទីបញ្ចប់គេចេះប្រើបំណិននោះនៅក្នុងស្ថានភាពថ្មី ។




ចូរព្យាយាមឱ្យកាន់តែដឹងអំពីដំណាក់កាលទាំងបីនេះ ខណៈដែលអ្នកបង្រៀនកូន ។ ចូរចងចាំផងដែរ កុមារគ្រប់រូបត្រូវការហ្វឹកហាត់យ៉ាងច្រើន មុនពេលដែលគេចេះបំណិនថ្មីមួយទាំងស្រុង ។

សកម្មភាពជាច្រើននៅក្នុងសៀវភៅតម្រូវឱ្យអ្នកជួយជ្រោមជ្រែងកូនពីដំបូងឱ្យបានច្រើន។ កាលណាកូនចាប់ផ្តើមចេះបំណិនមួយស្ទាត់ជំនាញហើយ ចូរបន្ថយការជួយរបស់អ្នកឱ្យកាន់តែតិចទៅៗ។ ឧទាហរណ៍ នៅពេលកូនអ្នកកំពុងរៀនហូបចុកដោយខ្លួនឯង :-




ដំបូងអ្នកអាចដាក់ដៃរបស់អ្នកលើដៃកូន ហើយចាប់លើកដៃរបស់កូន (តម្រង់មាត់)។




ខណៈដែលអ្នកមានអារម្មណ៍ថា កូនចាប់ផ្តើមធ្វើសកម្មភាពខ្លះៗដោយខ្លួនឯងហើយ ចូរបន្ធូរការកាន់ដៃកូន។ បន្ទាប់មករំកិលដៃអ្នកបន្តិចម្តងៗមកកាន់កដៃរបស់កូន ក្រោយមកទៀតមកកាន់កំភួនដៃកូន....




....ហើយបន្ទាប់ទៀតប្តូរមកកាន់កែងដៃកូន។

## លើកទឹកចិត្តកូនឱ្យម្ចាស់ការលើខ្លួនឯង

វាគឺជារឿងធម្មតាចំពោះការចង់ជួយកូនធ្វើអ្វីមួយ តែត្រូវប្រយ័ត្នចំពោះការជួយកូនហួសហេតុពេក ដែលធ្វើឱ្យគេគ្មានឱកាសរៀនពីព្រឹត្តិការណ៍ទាំងឡាយថាមានដំណើរការយ៉ាងណានោះ ។ ឧទាហរណ៍ :-



**នៅពេលកូនទម្លាក់ប្រដាប់លេងចោល**
**ធម្មតាអ្នកពិតជាចង់រើសវាឱ្យកូន...**




**...តែកូននឹងរៀនកាន់តែច្រើន បើសិនជាអ្នកជួយកូន**
**ឱ្យរកប្រដាប់លេងដោយខ្លួនឯង។**

## ចូរប្រើគំហើញរបស់កូនដែលនៅសេសសល់ឱ្យល្អបំផុត

បើកូនអ្នកអាចមើលឃើញតិចតួច ចូរព្យាយាមធ្វើសកម្មភាពដោយប្រើគំហើញដែលនៅសេសសល់ ។ ជំពូកបន្ទាប់នេះនឹងពន្យល់ណែនាំពីរបៀបអនុវត្ត ។

